**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍កោះខ្យង
# រយៈពេល ៣ឆ្នាំ ( កញ្ញា ២០២៥ - សីហា ២០២៨ )

**ឈ្មោះសហគមន៍នេសាទ** ៖ កោះខ្យង
ភូមិ ៖ អន់ឆ្អើត ខ្សាច់ក្រហម និងតាប៉ែន
ឃុំ ៖ ជីខក្រោម
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

រៀបចំដោយរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលកោះកុង ( គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព )

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ


**១- ស្ថានភាពទូទៅ**...............................................................................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.........................................................២

ក- ប្រជាពលរដ្ឋ.........................................................................................២

ខ-មុខរបរ..............................................................................................៣

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ**.................៣

ក- ទីតាំង................................................................................................៣

ខ- ដែននេសាទ.........................................................................................៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល.............................................៤

ឃ- ធនធានជលផល.....................................................................................៤

**៤- ការធ្វើនេសាទ**.....................................................................................៤

ក- អ្នកនេសាទ..........................................................................................៤

ខ- ឧបករណ៍នេសាទ...................................................................................៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ...............................................................៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**.............................................................៧

**ក- ទស្សនៈវិស័យ**.....................................................................................៧

**ខ- គោលបំណង**......................................................................................៧

**គ-ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**.......................................................៧

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**.........................................................៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ...................................................៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ................៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..........................................................៩

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ............................................................១០

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.............................................................១១

គ៦- ផែនការកែលម្អកន្លែងសហគមន៍នេសាទ........................................................១២

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.......................១៣

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ....................១៤

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.....................................................................១៤

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**...............................................១៥

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.......................................១៥

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ............................................១៧

គ១២- ផែនការបង្កើតតំបន់ទេសចរណ៍ជលផលរបស់សហគមន៍នេសាទ.............................១៨

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ............................................១៩

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**....................២០
គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ...........២០
គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ............................................២០
**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**.......................................................................២១
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន........................................................................២១
គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..........................................................២២
**ឃ. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**....................................................................២២
**ង. ផែនការយុទ្ធសាស្ត្រ**.......................................................................................................២៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បែកក្រង់ រយៈពេល៣ឆ្នាំ**..........................២៤
**តារាងពេលវេលាការងារ**...................................................................................................៣២

# ផែនការគ្រប់គ្រង
# កន្លែងសហគមន៍នេសាទ

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទកោះខ្យង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅឆ្នាំ២០០២ និងបានបោះឆ្នោតអាណត្តិទី៤ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣។ ហើយត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ២៨៥ ប្រក.កសក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។

សហគមន៍នេសាទកោះខ្យង មានទីតាំងស្ថិតនៅភូមិអន់ឆ្អើត ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង។ មានសមាជិកសហគមន៍នេសាទសរុបចំនួន៣២២នាក់ ស្រី៨២នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន១៥១គ្រួសារ មានគណៈកម្មការចំនួន១១នាក់ ស្រី២នាក់ និងមានក្រុមល្បាតចំនួន១០នាក់។

កន្លងមកនេះ សហគមន៍នេសាទបានរៀបចំនិងអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ បានចូលរួមកំណត់ព្រំប្រទល់និងធ្វើផែនទីកន្លែងនេសាទសហគមន៍បានរៀបចំបញ្ជីឈ្មោះសមាជិក បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ និងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្តដោយមានការឯកភាពគ្នាក្នុងចំណោមគណៈកម្មការសហគមន៍នេសាទទាំងអស់។ ក្រៅពីនេះសហគមន៍នេសាទ បានអនុវត្តសកម្មភាពសំខាន់ៗ រួមមានការចូលរួមប្រជុំ និងបិទប្រកាសផ្សព្វផ្សាយផែនទីកន្លែងសហគមន៍នេសាទ ការរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ រៀបចំធនាគារក្តាមសេះ ការចាប់ផ្តើមអនុវត្តសកម្មភាពមុខរបរនិងសកម្មភាពទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទចូលរួមប្រជុំផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលនានា ការរៀបចំក្រុមល្បាតរបស់សហគមន៍នេសាទរួមសហការជាមួយសមត្ថកិច្ចជលផលអាជ្ញាធរមូលដ្ឋាននិងអង្គភាពពាក់ព័ន្ធដទៃទៀតក្នុងការចុះល្បាតទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងសហគមន៍នេសាទ។ រហូតមកដល់បច្ចុប្បន្ននេះសហគមន៍នេសាទបានអនុវត្តសកម្មភាព តាមផែនការគ្រប់គ្រងរបស់ខ្លួនដោយទទួលបានវឌ្ឍនភាពប្រកបដោយជោគជ័យក្នុងការកាត់បន្ថយសកម្មភាពបទល្មើសជលផលនានា។

ទោះបីជាទទួលបានលទ្ធផលដូចខាងលើក្តីសហគមន៍នេសាទកោះខ្យង នៅបានជួបប្រទះបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ផលត្រីថយចុះ បរិមាណវារីសត្វថយចុះ ការបាត់បង់ប្រភេទត្រីសំខាន់ៗមួយចំនួន និងខ្វះទីជម្រក ដោយការរៀបចំកន្លែងអភិរក្សជលផលមិនទាន់ច្បាស់លាស់

- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ខ្វះបច្ចេកទេសសមស្របការដាំបន្លែ ខ្វះបច្ចេកទេសចិញ្ចឹមត្រីនិងចិញ្ចឹមសត្វ ខ្វះមុខរបរចិញ្ចឹមជីវិត ខ្វះសម្ភារ និងខ្វះពូជបន្លែ ការដាំដំណាំមិនបានផលល្អ មិនមានប្រភពទឹកគ្រប់គ្រាន់ តម្លៃផលកសិកម្មស្ថិតនៅលើឈ្មួញកណ្តាល តម្លៃពលកម្មក្នុងតំបន់មានតម្លៃទាប ស្ត្រីខ្វះមុខរបរ និងការងារ ស្ថានភាពយេឌ័រនៅមានកម្រិត ស្ថានភាពអនាម័យនៅមានកម្រិត ចំណេះដឹងនៅមានកម្រិត និងចំណាកស្រុក

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន សមត្ថភាពគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ការសហការជាមួយអ្នកពាក់ព័ន្ធនៅមានកម្រិត ខ្វះប្រភពថវិកា និងខ្វះសម្ភារមធ្យោបាយបង្ក្រាបបទល្មើសនេសាទ ជនល្មើសមិនខ្លាចក្រុមល្បាត អ្នកនេសាទខ្វះការយល់ដឹងពីច្បាប់ស្តីពីជលផល ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការអភិរក្សជលផលរបស់សហគមន៍នេសាទនិងក្នុងការទប់ស្កាត់បទល្មើសជលផល។ សមាជិកសហគមន៍នេសាទយល់ថាការងារជារបស់គណៈកម្មការសហគមន៍នេសាទ ជាតួនាទីរបស់បុរសចំណែកស្ត្រីមានតួនាទីជាអ្នក

ថៃទាំគ្រួសារធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីស្ត្រីមានការចូលរួមក្នុងកិច្ចប្រជុំនានាមានចំនួនច្រើនប៉ុន្តែការសម្រេចនៅមានកម្រិត។

ដូច្នេះទាមទារការរៀបចំកែសម្រួលនូវផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកោះខ្យង ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧ លេខ១១៥២ ជផ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤ ដោយរៀបចំផែនការសកម្មភាព សំខាន់ៗបន្ថែម និងថវិកាប៉ាន់ប្រមាណ ផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការចុះបញ្ជីនាវានេសាទ ការប្រមូលព័ត៌មាន (ទូកនេសាទ ឧបករណ៍នេសាទ និងផលនេសាទ) និងការកាត់បន្ថយការប្រើប្រាស់ឧបករណ៍ នេសាទខុសច្បាប់។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន ២ ១៧៣ នាក់ ស្រី ១ ០៦៣ នាក់ ក្នុងនោះមានចំនួន ៥១០ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ ៥១ នាក់ ស្រី ២៨ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ២៦៣ នាក់ ស្រី ៤៩ នាក់ កម្រិតវិទ្យាល័យចំនួន ៨ នាក់ ស្រីចំនួន ៥ នាក់ និងកម្រិតឧត្តមសិក្សាគ្មាន ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន៩នាក់ ស្រី៣នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៣៦នាក់ ស្រី៨នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន០នាក់ ស្រី០នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៦នាក់ ស្រី២នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន ៣២៣ គ្រួសារ
- ធ្វើស្រែចំនួន ៦៨ នាក់ ទំហំ១០០ ហិកតា
- ធ្វើចំការ ៥ គ្រួសារ ទំហំ២,៥ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៧ គ្រួសារ
- ជាងផ្ទះចំនួន ១៣ គ្រួសារ
- លក់ដូរចំនួន ១៤ គ្រួសារ
- កម្មករ ១៦ គ្រួសារ
- កែច្នៃផលិតផលជលផល ១៤ គ្រួសារ (បង្គាក្រៀម ក្តាមប្រៃ ត្រីងៀត និងទឹកត្រី)
- ចិញ្ចឹមសត្វ ៣៨គ្រួសារ
- ដឹកជញ្ជូនភ្ញៀវចំនួន ២គ្រួសារ
- ជួសជុលឧបករណ៍នេសាទ ៦គ្រួសារ
- ជួលជុលម៉ាញ៉េ ទូរទស្សន៍ ២គ្រួសារ។

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៦ ៥០០ ០០០ រៀល ។

## ៣ កន្លែងសហគមន៍នេសាទ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងសហគមន៍នេសាទកោះខ្យង ជាតំបន់គ្រប់គ្រងជលផលសមុទ្រ មានកន្លែងនេសាទតាមឆ្នេរ វាលភក់ កន្លែងអភិរក្សជលផល ស្មៅសមុទ្រ នាទីព្រៃកោងកាង កន្លែងវារីវប្បកម្មសមុទ្រ ជាតំបន់គ្រប់គ្រងជលផលដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិអន់ឆ្អើត ខ្សាច់ក្រហម តាបែន និងភូមិចំបក់ ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង។ កន្លែងសហគមន៍នេសាទកោះខ្យង មានទំហំ **៦ ៤៦២** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅ ក្នុងកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ។

សហគមន៍នេសាទកោះខ្យងមានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងត្បូងជាប់នឹងកន្លែងសហគមន៍នេសាទជ្រោយស្វាយ
- ខាងកើតជាប់នឹងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង
- ខាងលិចជាប់នឹងកន្លែងសហគមន៍នេសាទឃុំកណ្តាល និងកន្លែងសហគមន៍នេសាទតាមាយ។

### ខ. តំបន់គ្រប់គ្រងជលផល

កន្លែងសហគមន៍នេសាទកោះខ្យង មានលំហសមុទ្រចំនួន១ វាលភក់ចំនួន១ និងនាទីព្រៃកោងកាង ចំនួន១ គឺ៖

- លំហសមុទ្រ ទំហំ ៦៣១៦ ហិកតា នេសាទពេញមួយឆ្នាំ
- វាលភក់ ទំហំ ១៤៤ ហិកតា នេសាទពេញមួយឆ្នាំ
- នាទីព្រៃកោងកាង ទំហំ ២ ហិកតា នេសាទពេញមួយឆ្នាំ ។

### គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល

សហគមន៍នេសាទកោះខ្យង បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សជលផលចំនួន ២កន្លែង ស្ថិតនៅចំណុចបង្គោល១០០ ទំហំ ៧៩ ហិកតា និងស្ថិតនៅចំណុចកោះខ្យងទំហំ ២៨ ហិកតា។ កន្លែងអភិរក្សជលផលនេះ ត្រូវបានធ្វើការរៀបចំនិងគ្រប់គ្រងដោយសហគមន៍នេសាទ។

### ឃ. ធនធានជលផល

ប្រទេសកម្ពុជា ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង និងសេដ្ឋកិច្ច ហើយធនធានជលផល បានផ្តល់ជាអាហារនិងមុខរបរនៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ជាពិសេសអ្នកនេសាទវ័យចាស់។ តាមការបង្ហាញពីសហគមន៍ នេសាទកោះខ្យង បានឱ្យដឹងថា បច្ចុប្បន្នធនធាជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់មិនបានសមស្រប។

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្តចិន ត្រីក្បក ត្រីក្អុក ត្រីស្តុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកាឡាងំ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រែ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក ជាដើម។ល។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកន្ទួប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ទាយ បាលង្កកាស កញ្ចូ អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៉ឹង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ដើមទ្បេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៣២២នាក់ ស្រី៨២នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍១៨៧នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន២៥នាក់ ។

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៣៥ | ១៥០០ម៉ែត្រ /គ្រួសារ | ក្រទ្បា៣,៥ស.មទ្បើង | ពេញរដូវនេសាទ |
| មងត្រីការាវ | ម៉ែត្រ | ២៣ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រទ្បា៧ស.មទ្បើង | ពេញរដូវនេសាទ |
| មងបង្កងកណ្តប | ម៉ែត្រ | ២០ | ៤០-៥០ម៉ែត្រ/គ្រួសារ | ក្រទ្បា៣ស.ម | ពេញរដូវនេសាទ |
| លបក្តាមថ្ម | លប | ២០ | ៥០០គ្រឿង/គ្រួសារ | ក្រទ្បា៦ស.មទ្បើង | ពេញរដូវនេសាទ |
| លបក្តាមសេះ | លប | ២០ | ២៥០គ្រឿង/គ្រួសារ | ក្រទ្បា៦ស.មទ្បើង | ពេញរដូវនេសាទ |
| សន្ទូចរនងត្រី | ផ្លែ | ១៥ | ១០០-២០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | ឧសភាដល់ធ្នូ |
| សន្ទូចរនងបបែល | ផ្លែ | ២៥ | ៣០០-៥០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | មិថុនា-តុលា |
| បង្កៃ | ផ្លែ | ២០ | ១៥០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | ឧសភាដល់ធ្នូ |
| ឈិបរុញដោយដៃ | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ក្រទ្បា១,៥ស.មទ្បើង | ពេញរដូវនេសាទ |
| រាវគ្រែងឈាម | នាក់ | ១៥ | ២០០នាក់ | - | ពេញរដូវនេសាទ |
| ឈ្នាងអូសគ្រែងឈាម | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ក្រទ្បា១,៥ស.មទ្បើង | ពេញរដូវនេសាទ |
| រាវងាវភក់ | នាក់ | ២០ | - | - | ពេញរដូវនេសាទ |
| លូកក្តាមថ្ម ជ័រ | នាក់ | ១៧ | - | - | ពេញរដូវនេសាទ |
| មងត្រី | ម៉ែត្រ | ១៥ | ១០០០ម៉ែត្រ/គ្រួសារ | ក្រទ្បា ១០ ស.មទ្បើង | ឧសភាដល់ធ្នូ |
| លបត្រី | លប | ៣០ | ១០-២០លប/គ្រួសារ | ក្រទ្បា៦ស.មទ្បើង | ឧសភាដល់ធ្នូ |
| ទ្រូ | ទ្រូ | ៣ | ៩ទ្រូ/គ្រួសារ | - | ឧសភាដល់ធ្នូ |
| សំណាញ់ | វង់ | ១៥ | ១៥វង់/គ្រួសារ | ក្រទ្បា១,៥ស.មទ្បើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបន្តើត | ៩១ គ្រឿង | ៥០០-១៥០០គីទ្បូក្រាម | ៥-១៥ សេះ |
| ទូកអុំនិងចែវ | ៣ គ្រឿង | ៥០-១០០គីទ្បូក្រាម | - |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៣០ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីតាវ | ម៉ែត្រ | ១៨ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងក្តាម | ម៉ែត្រ | ១៩ | ៣០០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីកន្តាំង | ម៉ែត្រ | ២៤ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៤ស.មឡើង | ពេញរដូវនេសាទ |
| ផ្នាក់មឹកសំបកខ្យង | ម៉ែត្រ | ១៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសា |
| លបក្តាមសេះ | លប | ៣០ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមថ្ម | លប | ២០ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| សន្ទូចត្រីក្អុក | ផ្លែ | ៨ | ៣០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | មេសាដល់កក្កដា |
| សន្ទូចត្រីអណ្តែងប៉ុយ | ផ្លែ | ៥ | ៣០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | មេសាដល់កក្កដា |
| សន្ទូចបបែល | ផ្លែ | ៨ | ៥០០ផ្លែ/គ្រួសារ | - | មេសាដល់កក្កដា |
| ភាវគ្រែងឈាម/ងាវភក់ | នាក់ | ២ | ១នាក់ | - | ពេញរដូវនេសាទ |
| ឈិបរុញដោយដៃ | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | - | ពេញរដូវនេសាទ |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបន្ទើត | ២០ គ្រឿង | ៥០០-១៥០០គីឡូក្រាម | ៥-១៥ សេះ |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងក្តាម | ម៉ែត្រ | ៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីកាម៉យ | ម៉ែត្រ | ៨ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសា |
| មងត្រីស | ម៉ែត្រ | ៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| លបក្តាមសេះ | លប | ៣ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមថ្ម | លប | ៣ | ៥០០លប/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| ផ្នាក់មឹកសំបកខ្យង | ម៉ែត្រ | ១៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបន្ទើត | ២០ គ្រឿង | ៥០០-១៥០០គីឡូក្រាម | ៥-១៥ សេះ |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| **ប្រភេទផលនេសាទ** | **បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ)** | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីចម្រុះ | ៥ ៧០០ គីឡូក្រាម | ៣ ៣៥៨ គីឡូក្រាម | ៩ ០៥៨ គីឡូក្រាម |
| បង្គា | ៣១៥ គីឡូក្រាម | ២០៥ គីឡូក្រាម | ៥២០ គីឡូក្រាម |
| ក្ដាម | ២ ៥០០ គីឡូក្រាម | ៦៨០ គីឡូក្រាម | ៣ ១៨០ គីឡូក្រាម |
| មឹក ខ្យង និងគ្រែងឈាម | ៩០០ គីឡូក្រាម | ៣៥០ គីឡូក្រាម | ១ ២៥០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទកោះខ្យង មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រ ប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានជលផល។

**គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**

**ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង**

**គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចមាត់ទឹក ដីទំហំ ២០ម៉ែត្រ x ៣០ម៉ែត្រ ស្ថិតនៅក្នុងភូមិអន់ឆ្អើត ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុងត្រូវបានរៀបចំដូចខាងក្រោម ៖

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)** | **អ្នកចូលរួម** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ៥០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១២ម ធ្វើពីបេតុងរួមផ្សំគ្រឿងឈើ ប្រក់ក្បឿង រៀបចំបន្ទប់ជញ្ជាំងឥដ្ឋ និងមានបង្គន់អនាម័យ | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ | ៣០០០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| តបណ្ដាញអគ្គីសនី | មានថាមពលអគ្គីសនីធ្វើការ | ១៥០០ | | | |
| តនិងរៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជ័រ ២ ចំណុះ ៣ ៥០០លីត្រ | មានទឹកស្អាតប្រើប្រាស់ | ១២០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្ដារខៀន កៅអី កំព្យូទ័រ ព្រីនធើ LCD with Screen) | មានសម្ភារសម្រាប់ធ្វើការ | ១៥៥០ | | | |

(ម = ម៉ែត្រ, ស.ន = សហគមន៍នេសាទ)

## គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្ដាហ៍ទី១នៃខែរៀងរាល់ខែឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត<br>-លើកឡើងពីបញ្ហាប្រឈមនិងតម្រូវការ | ៧២០ | -គណៈកម្មការ<br>-ក្រុមល្បាត | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយអាជ្ញាធរឃុំ ស្រុក ឬអង្គភាពពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្ដល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំ<br>-មានដំណោះស្រាយ | ៦៥០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយបណ្ដាញស.ន ថ្នាក់ស្រុក ឬថ្នាក់ខេត្ត | | | -អាជ្ញាធរស្រុក/ខេត្ត<br>-បណ្ដាញស.ន | | |
| ចុះប្រជុំដើម្បីជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ | - បានចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសជលផលថយចុះ | ៦០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| សម្ភារការិយាល័យ<br>- LCD with Screen<br>-ទិញក្រដាស់ ប៊ិច ព្រីនឯកសារ កូពី<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ២០០០ | គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

## គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីសហគមន៍កសិកម្ម ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br>-ការរៀបចំនិងទុកដាក់សម្រាម<br>-បទពិសោធន៍នានាទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហកមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | ២៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | ឧសភា-ធ្នូ/ រៀងរាល់ឆ្នាំ | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | | |
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទ បានចុះបញ្ជីទូកម៉ាស៊ីនតាមច្បាប់ | ៤៥០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| ២.ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកានិងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ និងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១៥០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈកម្មការស.ន (២នាក់) | ៣៦០ | គណៈកម្មការស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | | ៤០០ | គណៈកម្មការ ជំនាញជលផល | | |

(ស.ន = សហគមន៍នេសាទ)

**គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទតំបន់គ្រប់គ្រងជលផល ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍កោះខ្យង | ពេញរដូវនេសាទ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៥០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | មងត្រីឆ្លង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីព្រលួស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រខុប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្តាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្តាម | ក្រឡា ៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្ទប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ទុយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាវ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគូន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្តាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រឹសច្រើន/កន្ទុយកណ្តុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមកៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខូវ ឬមងខូវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍កោះខ្យង | ពេញរដូវនេសាទ | អួនកេវ ឬមងកេវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងធ្នាក់មឹក | - | ៥០០គ្រ/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | ឈិបរុញដោយដៃ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |
| | | ភាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | ភាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្តាមថ្ម ជ័រ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ, គ្រ = គ្រាប់)

**គ៥-ផែនការទប់ស្កាត់បទល្មើសជលផល**

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ៖<br>-តាមមេក្រូ ២ដង/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ<br>-ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ សីហា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ១០០០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រជុំប្រចាំខែ ឬឆមាស (មិថុនានិងធ្នូ/រៀងរាល់ឆ្នាំ) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>អង្គភាពពាក់ព័ន្ធ | | |
| អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះល្បាតដល់ទីកន្លែង ដោយទំនាក់ទំនង និងឬ សហការជាមួយ អាជ្ញាធរមូលដ្ឋាន និងឬ អង្គភាពពាក់ព័ន្ធ) (៤ដង/ខែ = ១៤៤/ដង) | -បទល្មើសជលផលថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០៣៦៨ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ<br>អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| មធ្យោបាយនិងសម្ភារ -សាំងឬម៉ាស៊ុតនិងប្រេងបាត -អាវ ស្បែកជើង មួក អាវភ្លៀង អាវពោង ពិល អាយកូម ម៉ាស៊ីនថត កែវយ៉ិត កាតទូរស័ព្ទ | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ទិញអូប័រនិងម៉ាស៊ីន៤០សេះ ចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ៦០០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | | |
| កៀងគរថវិកាក្នុងការឧបបត្ថម្ភ ឬបដិភាគដល់ប្រជានេសាទដែលឈប់ឬផ្លាស់ប្តូរការប្រើឧបករណ៍នេសាទខុសច្បាប់ | កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ៥០០០ | | កញ្ញា ២០២៥ | សីហា ២០២៨ |

**គ.៦ ផែនការកែលម្អកន្លែងសហគមន៍នេសាទ**

ផែនការកែលម្អតំបន់គ្រប់គ្រងជលផល ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| តំបន់គ្រប់គ្រងជលផល | **ទំហំ** (ហិកតា) | **ទំហំដែលត្រូវកែលម្អ** | **សកម្មភាព** | **ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍កោះខ្យង | ៦ ៤៦២ | ៦ ៤៦២ ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ ស្ថាប័ន និងអ្នកពាក់ព័ន្ធ | ១០០ | សីហា ២០២៥ | កក្កដា ២០២៨ |
| | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ២ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ១២០០ | | |
| | | | ស្លាកសញ្ញាផ្សព្វផ្សាយ១០ផ្ទាំង១,២មx១ម គ្រឿងដែក(ដែកមូល) | ២០០០ | | |
| | | | កំណត់ទីតាំងតាមនិយាមកានិងបោះបង្គោលព្រំប្រទល់សហគមន៍នេសាទក្នុងទឹក ចំនួន ៩បង្គោល(មូល)ធ្វើពីបេតុងទំហំ០,៣មx៨ម | ៩០០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

### គ.៧ ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំត្រូវអភិរក្ស (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អភិរក្សជលផល<br>បង្គោល១០០<br>៧៩ ហិកតា<br>343812-1231207<br>343355-1230860<br>342536-1232009<br>342984-1232335 | ៧៩ | -ព្រៃកោងកាង<br>-ក្តាមជ័រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលនិងហាមឃាត់ដល់ប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ | ៨០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៦០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក(សាជី) ចំនួន៤បង្គោល | ២៨០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សជលផលភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ | ១៧០០ | | |
| | | -ត្រី ផ្សោត<br>-ជីវចម្រុះ | ចុះសិក្សាប្រមូលព័ត៌មាន | ៥០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ប្រជុំផ្សព្វផ្សាយពីកន្លែងសាងសង់ជម្រកសិប្បនិម្មិត | ៥០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន៦០ ប្រអប់ | ៦០០០ | | |
| អភិរក្សជលផល<br>កោះខ្យង<br>២៨ ហិកតា<br>347057-1226048<br>346945-1225671<br>346265-1225965<br>346415-1226335 | ២៨ | -គ្រែងឈាម<br>-ជីវចម្រុះ | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៦០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | បោះបង្គោលព្រំកន្លែងជម្រកសុវត្ថិភាពធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក(សាជី) ចំនួន៤បង្គោល | ២៨០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន៤០ ប្រអប់ | ៤០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |

### គ.៨ **ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពងរបស់សហគមន៍នេសាទ**

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពង ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកជលផល ដូចមាននៅក្នុងតារាងខាងក្រោម ៖

| **ឈ្មោះដែននេសាទ** | **ទំហំ (ហិកតា)** | **ប្រភេទ** | **សកម្មភាព** | **ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|---|
| ក្នុងកន្លែងសហគមន៍នេសាទកោះខ្យង<br>344700-1229148<br>344668-1229229<br>344782-1229274<br>344813-1229195 | ១<br>សាកល្បងជំហានទី១ទំហំ ២៥មx២៥ម | -ក្ដាមសេះ<br>-ស្មៅសមុទ្រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្ដាមសេះពង | ៣៦០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ជួសជុលស្ថានីយ៍១កន្លែងនិងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីឈើ និងសម្ភារជាង | ៥៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្ដាមសេះ និងព័ទ្ធស៊ែឡមុង | ៥០០ | | |
| | | | ពង្រាយប្រអប់ថ្មបេតុងត្រីសិប្បនិម្មិតធ្វើពី ចំនួន១០ប្រអប់ថ្មបេតុង | ៤០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្ដាម និងមេក្ដាមពង | ៥០០ | | |
| | | | ទិញឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់កូនក្ដាមសេះ | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |

(ម = ម៉ែត្រ)

### **គ.៩ ផែនការគ្រប់គ្រងព្រៃកោងកាង**

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| **ឈ្មោះដែននេសាទ** | **ទំហំ (ហ.ត)** | **ប្រភេទព្រៃឈើការពារ** | **សកម្មភាព** | | **ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ២ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងជាក់ស្ដែងតាមនិយាមកា | | ២០០ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ១០ស.ម x ១០ស.ម x ១,៥ម ចំនួន២០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាងសហគមន៍នេសាទកោះខ្យង | | ១៥០ | | |
| | | | ដាក់ស្លាកសញ្ញាផែនទីព្រៃកោងកាង១ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | | ៤០០ | | |
| | | | ថែរក្សា ការពារ | | | | |
| វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ | សរុប ១៨៤ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤៤ ហិកតា | | | រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាផែនទីព្រៃកោងកាង១ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | ៨០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាង បង្កោលឈើ និងស្បៃ ១០ម x ២០ម | ១០០០ | | |
| | | | បណ្តុះ ដាំ និងថែទាំដើមកោងកាងកាង១១ហិកតា ៥៥០០០ដើម (១ហិកតា x ៥០០០ដើម) | ៥៥០០០ | | |
| | | | ដាំកូនកោងកាងចំនួន១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | ៣០០០ | | |
| | | | ថែទាំដើមកោងកាង រយៈពេល៣ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ | ១០០០ | | |
| | | | ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ, ១ថ្ងៃ/អាទិត្យ | ១០០០ | | |
| | | | ពី៦ខែឡើងទៅ ៤នាក់x១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ | ១២០០ | | |

(ម = ម៉ែត្រ)

## ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

### គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១. ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | -មានចំណេះដឹងចិញ្ចឹមគ្រែងឈាម ក្តាមថ្ម ងាវភក់ ខ្យងចំពុទា -យកទៅអនុវត្តជាក់ស្តែងបាន | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចិញ្ចឹមក្តាមថ្ម | | ៩០០ | | | |
| ចិញ្ចឹមងាវភក់ | | ៩០០ | | | |
| ចិញ្ចឹមខ្យងចំពុះទា | | ៩០០ | | | |
| កែច្នៃផលនេសាទ | -មានចំណេះដឹង -មានមុខរបរ -បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | | |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ៩០០ | | | |
| បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ | -មានមុខរបរខ្នាតតូច ឬសិប្បកម្ម -បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល | -ក្រុមចុងភៅ -ក្រុមផ្ទះស្នាក់នៅ -ក្រុមដឹកជញ្ជូន -ក្រុមធ្វើយានយន្ត -ក្រុមផ្គត់ផ្គង់ផលកសិកម្ម -ក្រុមរោងលម្ហែ (កញ្ចះ) | ១០០០ | គណៈកម្មការនិងសមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ២. ទស្សនៈកិច្ចសិក្សា | | ២៥០០ | គណៈកម្មការនិងសមាជិស.ន | | |

| | | | | | |
|---|---|---|---|---|---|
| ៣. ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម<br>ក្រុមចិញ្ចឹមក្ដាមថ្ម<br>ក្រុមចិញ្ចឹមងាវភក់<br>ក្រុមចិញ្ចឹមខ្យងចំពុះទា | -មានក្រុមចិញ្ចឹមគ្រែងឈាម ក្ដាមថ្ម ងាវភក់ និងខ្យងចំពុះទា<br>-មានគ្រែងឈាម ក្ដាមថ្ម ងាវភក់ និងខ្យងចំពុះទាផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ក្រុមកែច្នៃផលនេសាទ ដោយផ្ដោតលើ ៖<br>-ក្រុមស្ត្រី<br>-ជនងាយរងគ្រោះក្នុងស.ន | -មានក្រុមកែច្នៃផលនេសាទ<br>-មានផលិតផលនេសាទផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ក្រុមដាំបន្លែ | -មានក្រុមដាំបន្លែ កសិកម្មចម្រុះ បន្ត | ៥០០ | | | |
| ក្រុមកសិកម្មចម្រុះ និង កសិកម្មបន្ត | -មានបន្លែផ្គត់ផ្គង់តម្រូវការ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | | | |

(ស.ន = សហគមន៍នេសាទ, ចិ = ចិញ្ចឹម)

**គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទ កូនត្រីពូជ | បរិមាណ កូនត្រីពូជ | ប៉ាន់ស្មាន តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមគ្រែងឈាម ទំហំ ៣៩,៨២ ហិកតា<br>347236-1225560<br>347922-1225298<br>347705-1224800<br>347043-1225024 | សាកល្បង ២ ហិកតា បង្គោលឈើចម្រុះ ៣៥០ ដើម x ៨០០០រៀល | គ្រែងឈាម | - | ៩០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | របាំងសាច់អួន | | - | ១៥០០ | | |
| | កូនពូជគ្រែងឈាម | | ១០០០ក | ៣៧៥០ | | |
| ក្រុមចិញ្ចឹមក្ដាមថ្ម ទំហំ ៣ ហិកតា<br>351562-1225764<br>351746-1225708<br>351716-1225560<br>351513-1225625 | ប្រជុំផ្សព្វផ្សាយ | ក្ដាមថ្ម | - | ២០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | សាកល្បង ១ ហិកតា ស្ពារប្រឡាយព័ទ្ធជុំវិញ ១ម x ១ម | | - | ៥០០ | | |
| | បិទបាំងហ្វីហ្វូស៊ីម៉ង់ ជុំវិញ ចំនួន ៤០០ សន្លឹក | | - | ១៥០០ | | |
| ក្រុមចិញ្ចឹមងាវភក់<br>351756-1225703<br>351874-1225656<br>352030-1225581<br>351949-1225422 | ប្រជុំផ្សព្វផ្សាយ | ងាវភក់ | - | ៣០០ | | |
| | បង្គោលឈើ ៦០ បង្គោល (៣៥ ០០០រៀល/បង្គោល) | | - | ៥២៥ | | |
| | ស្លាកប្រាប់ទីតាំង ៥ស្លាក | | - | ២៥ | | |
| | កូនពូជងាវភក់ | | ២០០គ | ៤០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| 351843-1225492<br>351757-1225615 | | | | | | |
| ក្រុមចិញ្ចឹមខ្យងចំពុះទា | ប្រជុំផ្សព្វផ្សាយ | ខ្យងចំពុះទា | - | ២០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| ទំហំ ៨ ហិកតា<br>342843-1230495<br>343091-1230659 | សាកល្បង ១ ហិកតា<br>បង្គោលឈើចម្រុះ២៥០ជុំរុំ<br>(ជុំរុំ/៥ដើម x ៦០០០រៀល) | | - | ១៨៧៥ | | |
| 343250-1230431 | ខ្សែចងទីតាំងចិញ្ចឹម | | - | ៥០ | | |
| 343012-1230280 | ពូជខ្យងចំពុះទា | | ១០០គ | ២០០ | | |

(ម = ម៉ែត្រ, ក = ក្បាល, គ = គីឡូក្រាម )

**គ១២- ផែនការបង្កើតតំបន់ទេសចរណ៍ជលផលក្នុងសហគមន៍នេសាទ**

ផែនការបង្កើតតំបន់ទេសចរណ៍ជលផលក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងនៅតាមឆ្នេរសមុទ្រ ព្រៃកោងកាង ដងព្រៃកនានា និងទេសភាពកន្លែងសហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
